ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: [illegible]

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីត្រៀមរៀបចំ កិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការ និង ការអភិវឌ្ឍន៍ ខេត្តជាប់ព្រំដែនកម្ពុជា វៀតណាម លើកទី៣

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**ប្រការ១ :**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំកិច្ចប្រជុំស្តីពី កិច្ចសហប្រតិបត្តិការ និង ការអភិវឌ្ឍន៍ខេត្តជាប់ព្រំដែនកម្ពុជា វៀតណាម លើកទី៣ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១-ឯកឧត្តម ញ៉ាំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម ឡុង វិសាលោ | រដ្ឋលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

vn361

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៣-ឯកឧត្តម | **ទីយ ឡើន** | អគ្គលេខាធិការរង រាជរដ្ឋាភិបាលកម្ពុជា | សមាជិក |
| ៤- ឯកឧត្តម | **សក់ សេដ្ឋា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ឧត្តមសេនីយ៍ឯក | **ម៉ៅ ចំនួនតារា** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ៦-ឧត្តមសេនីយ៍ឯក | **ឈុំ សុជាតិ** | មេបញ្ជាការទីចាត់ការព្រំដែន អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៧-ឯកឧត្តម | **ជាវ សាវី** | អ្នកបកប្រែភាសាវៀតណាម | សមាជិក |
| ៨-ឧត្តមសេនីយ៍ឯក | **ចាន់ អ៊ីវន** | ប្រធាននាយកដ្ឋានកណ្តាលព្រំដែន នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ៩-ឧត្តមសេនីយ៍ទោ | **ថោង លឹម** | ប្រធាននាយកដ្ឋានជនបរទេស នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១០-ឧត្តមសេនីយ៍ត្រី | **ទន ឈុនលី** | ប្រធាននាយកដ្ឋានព្រំដែនទឹក នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១១-ឧត្តមសេនីយ៍ត្រី | **ញាណ ចិប៉ុល** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ២ :**

គណៈកម្មការខាងលើនេះ មានភារកិច្ចដូចខាងក្រោម ÷

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា នៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំខ្លឹមសារសំរាប់គណៈប្រតិភូដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចូលរួមក្នុងកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ខេត្តជាប់ព្រំដែនកម្ពុជា វៀតណាម លើកទី៣ ស្របតាមគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកលើខ្លឹមសារដែលបានសម្របសម្រួលខាងលើនេះ ដើម្បីពិភាក្សាជាមួយភាគីវៀតណាម សហការរៀបចំខ្លឹមសារប្រជុំអោយបានសមស្រប ។

**ប្រការ៣ :**

- ប្រធានគណៈកម្មការត្រូវរាយការណ៍សុំយោបល់ដឹកនាំជាប្រចាំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អនុប្រធាន និង សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំ និង ទទួលភារកិច្ចតាមការចាត់ចែង របស់ប្រធានគណៈកម្មការ
- គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រា និង ប្រើប្រាស់ថវិការបស់ក្រសួងមហាផ្ទៃ ក្នុងការចាត់ចែងការងាររបស់ខ្លួន ។

vn3b1

www.pheakdeylaw.com

**ប្រការ៤ :**

ក្នុងការសំរបសំរួលខ្លឹមសារនៃកិច្ចប្រជុំ គណៈកម្មការមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន ពាក់ព័ន្ធចូលរួមតាមការចាំបាច់ ។

**ប្រការ៥ :**

គណៈកម្មការត្រូវបញ្ចប់ការងាររបស់ខ្លួន បន្ទាប់ពីកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការ និង ការអភិវឌ្ឍន៍ខេត្តជាប់ព្រំដែនកម្ពុជា វៀតណាម លើកទី៣ ត្រូវបានបញ្ចប់រួចរាល់និងបន្ទាប់ពីបានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូនប្រមុខរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា នៃរាជរដ្ឋាភិបាលកម្ពុជា ។

**ប្រការ៦ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និង ឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

vo3b1

www.pheakdeylaw.com